ព្រឹត្តិបត្រព័ត៌មាន

# គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ

NGO Committee on the Rights of the Child

NGO CRC

ឆ្នាំទី៣ លេខ៨ ខែកក្កដា_កញ្ញា ឆ្នាំ២០០៥

មាតិកា ទំព័រ

សន្និសីទពិភពលោកលើកទី២ស្តីពីពលកម្មកុមារ និងការអប់រំ........១

វេទិកាកុមារC8.................២

ករណីរំលោភសេពសន្ថវៈនៅតែកើតមានយ៉ាងសាហាវ............៤

ការប្រគល់រង្វាន់ដល់កុមារជាប់ចំណាត់ថ្នាក់នៃការប្រលងគំនូរ.....៦

អង្គការយុវជនខ្មែរបោះជំរំដើម្បីវប្បធម៌....................៧

## សន្និសីទពិភពលោកលើកទី២ ស្តីពីពលកម្មកុមារ និងការអប់រំ




សន្និសីទពិភពលោកលើកទី២ស្តីពីពលកម្មកុមារ និងការអប់រំ ត្រូវបានរៀបចំឡើងដោយ Global March Against Child Labor ដែលប្រារព្ធធ្វើនៅថ្ងៃទី៤_៨កញ្ញា ២០០៥ នៅញូដេលី ប្រទេសឥណ្ឌា។ កុមារចូលរួមក្នុងឱកាសនោះ ជាតំណាងកុមារមានអាយុពី១៣ទៅ១៧ឆ្នាំ មានចំនួន២០០នាក់ដែលត្រូវបានជ្រើសរើសចេញពីប្រទេសចំនួន៤០ ក្នុងចំណោមប្រទេសទាំងនោះក៏មានប្រទេសកម្ពុជាផងដែរ។

សន្និសីទនេះរៀបចំឡើងដើម្បីឱ្យតំណាងកុមារជុំវិញពិភពលោកបានជួបជុំគ្នាចែករំលែកនូវបទពិសោធន៍ស្តីពីពលកម្មកុមារ ដើម្បីជជែកពិភាក្សារកបញ្ហាដែលកុមារប្រឈមមុខនឹងពលកម្មធ្ងន់ធ្ងរ និងបង្កើតនូវពង្រាងសេចក្តីថ្លែងការណ៍ដែលពួកគេគិតថា ជាបញ្ហាចាំបាច់សំរាប់ឱ្យមេដឹកនាំពិភពលោកដោះស្រាយនៅក្នុងការផ្តល់នូវការលុបបំបាត់ពលកម្មកុមារ និងផ្តល់នូវការអប់រំដល់កុមារទាំងអស់ក្នុងពិភពលោក។

លោក មាស សំណាង អនុប្រធានគណៈកម្មាធិការប្រតិបត្តិរបស់គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ(គ.អ.ស.ក) បានជូនតំណាងកុមារកម្ពុជាទៅចូលរួមក្នុងសន្និសីទនោះ មានប្រសាសន៍ថា សន្និសីទលើកទី២នេះ រៀបចំឡើងដើម្បីឱ្យតំណាងកុមាររបស់ប្រទេសមួយចំនួនដែលខកខានមិនត្រូវបានផ្តល់ទិដ្ឋាការ

ឱ្យដោយរដ្ឋាភិបាលប្រទេសអ៊ីតាលីក្នុងការចូលរួមក្នុងសន្និសីទពិភពលោកលើកទី១ស្តីពីពលកម្មកុមារ នៅហ្លូរ៉ង់ ប្រទេសអ៊ីតាលីនោះ បានចូលរួមបញ្ចេញនូវទស្សនៈយោបល់អំពីបញ្ហាដែលប្រទេសគេជួបប្រទះ។

លោកបន្តថាកាលពីសន្និសីទលើកទី១ ប្រទេសកម្ពុជាមានតំណាងកុមារពីររូបបានទៅចូលរួមក្នុងឱកាសនោះគឺកុមារីវង្ស រតនា និងកុមារា ឆន សូវៀត។ នៅក្នុងសន្និសីទលើកទី២នេះ កុមារី វង្ស រតនាត្រូវបានគេអញ្ជើញឱ្យទៅចូលរួមនោះ គឺថាដោយសារនាងត្រូវបានគេជ្រើសរើសចូលទៅក្នុងគណៈកម្មាធិ-ការពង្រាងសេចក្តីថ្លែងការណ៍ចេញពី Global March ដូច្នេះហើយទើបប្អូនស្រីបានទៅចូលរួមទៀត។

លោកបន្តទៀតថា សន្និសីទនេះផ្តោតសំខាន់លើការផ្តល់នូវយោបល់អំពីលទ្ធផលរបស់ប្រទេសនីមួយៗថាតើបានកែប្រែអ្វីខ្លះ បន្ទាប់ពីបានចូលរួមក្នុងសន្និសីទលើកទី១ ហើយប្រទេសនីមួយៗនឹងមានផែនការសកម្មភាពអ្វីទៀត ដើម្បីបន្តអនុវត្តក្នុងការចូលរួមប្រឆាំងនឹងពលកម្មកុមារ និងផ្តល់អាទិភាពឱ្យកុមារទទួលបាននូវការអប់រំគ្រប់ៗគ្នា។

កុមារី វង្ស រតនា តំណាង*បណ្តាញកុមារអ្នកតស៊ូមតិ*

***តនៅទំព័រទី៨***

# វេទិកាកុមារ C8

វេទិកាកុមារC8ត្រូវបានរៀបចំដោយអង្គការយូនីសេហ្វ ក្នុងគោលបំណងផ្តល់ឱកាសឱ្យតំណាងកុមារ និងយុវវ័យមកពីប្រទេសក្រីក្រចំនួន៨នៅលើពិភពលោក ជួបជុំគ្នាដើម្បីជជែកពិភាក្សាបង្កើតនូវពង្រាងសេចក្តីប្រកាសមួយស្តីពីបញ្ហាដែលកើតមាននៅក្នុងប្រទេសរបស់ពួកគេ។

ពង្រាងសេចក្តីប្រកាសនេះជាអនុសាសន៍មួយដែលបង្កើតឡើងដើម្បីផ្ញើជូនដល់មេដឹកនាំG8 ដើម្បីឱ្យគេដាក់បញ្ចូលទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំរបស់គេ ក្នុងបំណងឱ្យគេជួយដោះស្រាយនូវបញ្ហាទាំងនោះ។

វេទិកានេះត្រូវបានធ្វើឡើងកាលពីថ្ងៃទី៣-៥ខែកក្កដា ឆ្នាំ២០០៥ នៅប្រទេសស្កុតឡែន។ ក្នុងឱកាសនោះ តំណាងកុមារដែលចូលរួមមានអាយុចន្លោះពី១១ដល់១៨ឆ្នាំ មកពី Cambodia, Bhutan, Moldova, Yemen, Guinea, Sierra Leone, Lesotho, និង Bolivia និងយុវវ័យដែលមកពីប្រទេស G8 មាន Russia, France, Italy, Germany, និង UK ចូលរួមផងដែរ។

កុមារី ស៊ូ ធីតា មកពីក្លឹប*មិត្តបង្រៀនមិត្ត* នៃខេត្តរតនៈគីរី ជាតំណាងកុមារកម្ពុជា បានទៅចូលរួមក្នុងឱកាសនោះប្រាប់ថា អនុសាសន៍ដែលពួកគេបានបង្កើតមាន៨ចំនុចដែលនិយាយអំពីភាពក្រីក្រ ការអប់រំ ហ៊ីវ-អេដស៍ អនាម័យ ការចូលរួម អំពើហិង្សាលើកុមារ ពលកម្មកុមារ និងសុខមាលភាពកុមារ។

ប្អូនស្រីបានឱ្យដឹងទៀតថា នៅពេលដែលតំណាងកុមារឡើងបង្ហាញពីអនុសាសន៍ទាំងនោះ គឺមានមនុស្សរាប់ម៉ឺននាក់គាំទ្រ។ ហើយលោក McConnell រដ្ឋមន្ត្រីទី១ នៃប្រទេសស្កុតឡែនបាននិយាយថា «យើងសង្ឃឹមថាមេដឹកនាំនៃប្រទេសមហាអំណាច ដែលនឹងមកដល់ប្រទេសស្កុតឡែនក្នុងអាទិត្យនេះ មានឱកាសដើម្បីដោះស្រាយនូវអ្វីដែលយើងទាំងអស់គ្នាបានលើកឡើង»។

## *ខាងក្រោមនេះជាអនុសាសន៍នៃវេទិកាកុមារC8 ត្រូវបានបកប្រែជាភាសាខ្មែរក្រៅផ្លូវការ ចេញពីអត្ថបទ «Children for Change» :*

១. ភាពក្រីក្រគ្មានទៀតទេ!

- មេដឹកនាំG8ត្រូវតែលុបបំបាត់នូវភាពក្រីក្រជាបន្ទាន់។

២. ការអប់រំពេលបច្ចុប្បន្ន!

- មេដឹកនាំG8ត្រូវតែធ្វើឱ្យប្រាកដនូវការអប់រំដែលមានគុណភាព ដោយមិនបង់ប្រាក់ សំរាប់កុមារទាំងអស់។

៣. អំពើហិង្សាលើកុមារដល់ពេលបញ្ចប់!

- មេដឹកនាំG8ត្រូវតែការពារកុមារដោយពង្រឹងការលុបបំបាត់អំពើហិង្សាលើកុមារគ្រប់រូបភាពទាំងអស់ ពិសេសអំពើហិង្សាក្នុងគ្រួសារ សាលារៀន ទីសាធារណៈ កន្លែងធ្វើការ សហគមន៍ ប្រព័ន្ធផ្សព្វផ្សាយ ពេលមានសង្គ្រាម និងពេលមានជំលោះប្រើអាវុធ។

៤. ការចូលរួម លទ្ធិប្រជាធិបតេយ្យ និងអភិបាលកិច្ច មានកាន់តែច្រើនឡើងថែមទៀត!

- មេដឹកនាំG8ត្រូវតែគាំទ្រក្នុងការបង្កើតអ្នកតំណាងរបស់កុមារនៅគ្រប់ប្រទេស និងផ្តល់ឱកាសដល់កុមារក្នុងការចូលរួមធ្វើការសំរេចចិត្តគ្រប់ជាន់ថ្នាក់។
- មេដឹកនាំG8ត្រូវតែធ្វើឱ្យប្រាកដនូវការទទួលខុសត្រូវរបស់រដ្ឋាភិបាលដែលជំរុញឱ្យមានលទ្ធិប្រជាធិបតេយ្យ តម្លាភាព និងគ្មានការរើសអើងភេទ ពូជសាសន៍ អាយុ មនុស្សស្ថិតក្នុងតំរូវការពិសេស សាសនា និងសញ្ជាតិ។

៥. មេរោគអេដស៍ និងជំងឺអេដស៍គឺគ្មាន!

- មេដឹកនាំG8ត្រូវតែបង្កើតថ្នាំប្រឆាំងនឹងជំងឺ និងការព្យាបាលរោគដោយមិនគិតថ្លៃសំរាប់មនុស្សទាំងអស់គ្នា។ ការចំណាយទៅលើកម្មវិធីជំងឺអេដស៍ត្រូវតែត្រូវបានត្រួតពិនិត្យយ៉ាងតឹងរឹង ដូច្នេះវាឈានទៅដល់អ្វីដែលយើងត្រូវការបំផុតនោះ។
- មេដឹកនាំG8ត្រូវតែគាំទ្រនូវកម្មវិធីអប់រំដើម្បីទប់ស្កាត់មេរោគអេដស៍ និងជំងឺអេដស៍ និងទប់ស្កាត់ការរើសអើងចំពោះអ្នកឆ្លងមេរោគអេដស៍។ ស្រោមអនាម័យគួរតែផ្តល់ឱ្យយុវវ័យដោយឥតគិតថ្លៃ។

៦. កុមារធ្វើការងារត្រូវដោះស្រាយ!

- មេដឹកនាំG8ត្រូវតែគាំទ្រកម្មវិធីសំរាប់ការការពារ ការអប់រំ និងសុខភាពរបស់កុមារអនាថា និងកុមារដែលធ្វើការធ្ងន់។
- មេដឹកនាំG8ត្រូវតែធានានូវការអនុវត្តន៍ច្បាប់ប្រកបដោយប្រសិទ្ធិភាពសំរាប់បំបាត់ចោលនូវពលកម្មកុមារជាលំដាប់។
- មេដឹកនាំG8ត្រូវតែគាំទ្រ និងស្តាប់នូវការវិវត្តន៍នៃកុមារធ្វើការធ្ងន់ធ្ងរទាំងនៅក្នុងតំបន់ និងពិភពលោក។

៧. មានបរិស្ថានល្អ ទឹកស្អាត និងអនាម័យល្អ គ្រប់គ្រាន់សំរាប់ទាំងអស់គ្នា!

- មេដឹកនាំG8ត្រូវតែគាំទ្រនូវការចូលរួមរបស់កុមារក្នុងការពិនិត្យតាមដាន និងការការពារបរិស្ថានធម្មជាតិដើម្បីគាំទ្រដល់ការអភិវឌ្ឍន៍ប្រកបដោយសុវត្ថិភាពសំរាប់ថ្ងៃអនាគត។
- មេដឹកនាំG8ត្រូវតែអនុវត្តនូវពិធីសារKyoto។
- មេដឹកនាំG8ត្រូវតែគាំទ្ររដ្ឋាភិបាលដើម្បីបង្កើតឱ្យមានទឹកស្អាត អនាម័យល្អនៅក្នុងសាលារៀន និងសហគមន៍នានា។

៨. សុខមាលភាព និងចំណីអាហារមានគ្រប់គ្រាន់!

- មេដឹកនាំG8ត្រូវតែលុបចោលនូវបំណុល និងលើកកំពស់ការធ្វើពាណិជ្ជកម្មដោយយុត្តិធម៌ ដើម្បីធានាថាមូលនិធិទាំងឡាយត្រូវបានបង្កើតសំរាប់សេវាសុខភាព និងអាហារូបត្ថម្ភដែលផ្តល់ឱ្យដោយមិនគិតថ្លៃ។ ដូច្នេះកុមារពិតជាមិនស្លាប់ដោយសារជំងឺដែលអាចបង្ការបានដូចជាជំងឺគ្រុនចាញ់ ហើយកុមារទាំងនោះរស់នៅប្រកបដោយសុខភាពល្អ។
- មេដឹកនាំG8ត្រូវតែផ្សព្វផ្សាយពីរបៀបប្រើប្រាស់ឱសថដែលមានប្រសិទ្ធិភាព និងសុវត្ថិភាព៕

# ករណីរំលោភសេពសន្ថវៈនៅតែកើតមានយ៉ាងសាហាវ

ការរំលោភសេពសន្ថវៈជាការបំពារបំពានដោយចេតនាទៅលើជនរងគ្រោះ ដែលករណីនេះបណ្តាលអោយស្ត្រី និងកុមារជាច្រើនរងរបួសយ៉ាងធ្ងន់ធ្ងរទាំងផ្លូវកាយ និងផ្លូវចិត្ត ហើយជនរងគ្រោះខ្លះត្រូវបានបាត់បង់ជីវិតដោយសារជនល្មើសរំលោភហើយសំលាប់ចោល និងខ្លះទៀតត្រូវបានឆ្លងជំងឺផ្សេងៗដូចជាជំងឺអេដស៍ និងកាមរោគជាដើម។

ក្នុងរយៈពេល៩ខែនៃដើមឆ្នាំ២០០៥នេះ គ.អ.ស.ក ទទួលបានករណីរំលោភសេពសន្ថវៈចំនួន១២៥ករណីដែលជាករណីកើតឡើងច្រើនជាងករណីផ្សេងៗទៀត បើប្រៀបធៀបនឹងឆ្នាំ២០០៤ដែលមានតែ១០៥ករណីប៉ុណ្ណោះ។

តាមការសិក្សាលើករណីរំលោភសេពសន្ថវៈចំនួន១២៥ករណីនេះបានឱ្យដឹងថា មានកុមារីរងគ្រោះចំនួន១២៨នាក់ និងមានជនល្មើសចំនួន១២៦នាក់។

ក្នុងចំនោមកុមារីរងគ្រោះចំនួន១២៨នាក់ កុមារីអាយុក្រោម៥ឆ្នាំមានចំនួន៣,១៣% អាយុចន្លោះពី៥ដល់១០ឆ្នាំមានចំនួន២៨,១៣% ពី១១ដល់១៤ឆ្នាំមានចំនួន៣៨,២៨% និងពី១៥ដល់១៧មានចំនួន៣០,៤៧%។ កុមារីរងគ្រោះតែងតែទទួលនូវការគំរាមកំហែងពីជនល្មើសដោយគេនិយាយថា បើហ៊ានស្រែក ឬប្រាប់គេ គេនឹងសំលាប់ចោលជនរងគ្រោះចោល ឬសំលាប់ចោលទាំងគ្រួសារ។

រីឯជនល្មើសវិញ ក្នុងចំណោម១២៦នាក់ មានកុមារប្រព្រឹត្តបទល្មើសអាយុក្រោម១៨ឆ្នាំចំនួន១៥,០៨%។ ជនល្មើសអាយុចន្លោះពី១៨_៤៥ចំនួន៧៣,០២%។ ជនល្មើសអាយុចាប់ពី៤៦ឆ្នាំឡើងទៅចំនួន១១,៩០%។ ជនល្មើសទាំងនោះត្រូវបានឃុំឃាំងបណ្តោះអាសន្នចំនួន៨៨នាក់ មិនទាន់បានចាប់ខ្លួនចំនួន២៧នាក់ ជាប់គុកមានចំនួន៤នាក់ និងចំនួន៧នាក់ទៀតមិនត្រូវបានបញ្ជាក់ទេ។

ជនល្មើសភាគច្រើនជាអ្នកជិតខាងមានចំនួន២២,៩២% អ្នកភូមិមានចំនួន២១,៦២% សាច់ញាតិ៨,១១% ឪពុកចុង១០,៨១% ឪពុកបង្កើត៣,៦០% អ្នកស្គាល់គ្នា១២,៦១% និងចំនួន២០,៧២%មិនត្រូវបានបញ្ជាក់អំពីទំនាក់ទំនងរវាងជនល្មើសនិងជនរងគ្រោះទេ។

ករណីរំលោភសេពសន្ថវៈភាគច្រើន គឺកើតមាននៅខេត្តបន្ទាយមានជ័យ បាត់ដំបង កំពង់ធំ ភ្នំពេញ និងកណ្តាល។

ចំពោះមូលហេតុដែលនាំអោយជនល្មើសមានឱកាសអាចប្រព្រឹត្តអំពើរំលោភសេពសន្ថវៈលើកុមារីនោះបាន គឺច្រើនតែនៅពេលដែលកុមារីរងគ្រោះទៅឃ្វាលគោ ទៅរកត្រី ទៅរកអុសតែម្នាក់ឯង។ កុមារីរងគ្រោះនៅម្នាក់ឯងនៅពេលម្តាយទៅធ្វើស្រែចំការ ទៅរកស៊ីឆ្ងាយដោយទុកឱ្យកូននៅចាំផ្ទះ ធ្វើឱ្យល្មើសដែលនៅផ្ទះជិតគ្នា ឬឪពុកបង្កើត ឪពុកចុងមានឱកាសល្អ។ កុមារីដើរពេលយប់ម្នាក់ឯងនៅពេលមានពិធីអ្វីមួយនៅក្នុងភូមិ ដូចជាពេលចូលឆ្នាំខ្មែរមានពិធីរាំលេងកំសាន្តនៅពេលយប់ ឬទៅមើលទូរទស្សន៍នៅផ្ទះជនល្មើស។ ដោយសារតែភាពក្រីក្រកុមារីរងគ្រោះចាញ់បោកជនល្មើស ដោយជនល្មើសហៅឱ្យទៅជួយរាវត្រីដោយសន្យាថាឱ្យលុយ ឬហៅឱ្យមកជួយធ្វើជាព្រូឡានដោយសន្យាថាឱ្យលុយ១០០០០រៀលក្នុងមួយថ្ងៃ។ ជនល្មើសប្រើល្បិចលួងលោមថានឹងរៀបការជាមួយ ឬសន្យាថានឹងទិញក្រវិលឱ្យ ឬប្រើកុមារីឱ្យជួយទៅទិញអ្វីមួយ ឬប្រាប់ថាមានរឿងចង់និយាយប្រាប់ ឬបបួលទៅធ្វើការនៅប្រទេសថៃ។ កុមារីរងគ្រោះទៅបំរើជនល្មើសដើម្បីដោះបំណុលដែលឪពុកម្តាយជំពាក់ និងកុមារីរងគ្រោះធ្វើដំណើរទៅសាលារៀនផ្លូវឆ្ងាយតែម្នាក់ឯង។

ករណីទាំងអស់ខាងលើនេះ ជនល្មើសភាគច្រើនមានកំរិតវប្បធម៌ទាប ហើយពួកគេភាគច្រើនបានសារភាពនៅចំពោះមុខសមត្ថកិច្ចថា ពួកគេពិតជាបានប្រព្រឹត្តអំពើនោះពិតប្រាកដមែន។ ហើយមូលហេតុគឺដោយសារមកពីពួកគេផឹកស្រាស្រវឹងខ្លាំងពេកទើបប្រព្រឹត្តអំពើនេះដោយមិនដឹងខ្លួន។ អ្នកខ្លះទៀតនិយាយថា មកពីពួកគេប្រើប្រាស់ថ្នាំញៀនទើបធ្វើឱ្យពួកគេសប្បាយ និងមានអារម្មណ៍ចង់រួមភេទ។ អ្នកខ្លះទៀតនិយាយថាមកពីពួកគេមើលវីដេអូឬទស្សនាវដ្តីដែលមានរូបភាពអាសអាភាសទើបធ្វើឱ្យពួកគេមានអារម្មណ៍ចង់រួមភេទ។ ហើយអ្នកខ្លះទៀតនិយាយថា ពួកគេខ្លាចសង្សារបែកចិត្ត ទើបចង់បានខ្លួននាងឱ្យបានមុនគេ និងអ្នកខ្លះទៀតថា ដោយសារប្រពន្ធរបស់ខ្លួនទៅរកស៊ីនៅឆ្ងាយ ហើយខ្លួនមានអារម្មណ៍ចង់រួមភេទទើប

ឈានទៅរកការចាប់រំលោភសេពសន្ថវៈលើកុមារីក្មេងៗតែម្តង ព្រោះគេយល់ថា កុមារីជាមនុស្សដែលមានកំលាំងខ្សោយមិនអាចតដៃជាមួយពួកគេបាន និងងាយស្រួលក្នុងការបោកប្រាស់ និងសំឡុតគំរាមកំហែង។

ក្នុងចំណោម១២៥ករណីខាងលើ យើងសង្កេតឃើញថា មានកុមារីរងគ្រោះចំនួន៧នាក់ បានស្លាប់បាត់បង់ជីវិតដោយសារជនល្មើសសំលាប់ បន្ទាប់ពីចាប់រំលោភសេពសន្ថវៈរួច។

ករណីរំលោភសេពសន្ថវៈដែលបានរៀបរាប់ខាងលើ គ.អ.ស.កទទួលបានមកពីអង្គការសមាជិក និងអត្ថបទសារព័ត៌មានក្នុងស្រុក។

ដើម្បីរួមចំណែកក្នុងការកាត់បន្ថយការរំលោភផ្លូវភេទលើកុមារ សមត្ថកិច្ច និងតុលាការគួរតែរឹតបន្តឹងការអនុវត្តន៍ច្បាប់ដោយតាមចាប់ខ្លួនជនល្មើស និងជនល្មើសដែលចាប់រួចហើយ គួរតែកាត់ទោសទៅតាមច្បាប់។ ចំណែកឯអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិវិញ គួរបង្កើននូវការជួយផ្សព្វផ្សាយអំពីផលប៉ះពាល់នៃការរំលោភលើកុមារ បង្កើនការយល់ដឹងដល់ប្រជាជន និងជួយដល់កុមាររងគ្រោះនៅពេលដែលមានករណីរំលោភកើតឡើង ព្រមទាំងជួយការពារកុមារឱ្យរួចផុតពីការរំលោភបំពាន។ ចំពោះប្រជាពលរដ្ឋ ជាពិសេសឪពុកម្តាយ អាណាព្យាបាលមិនគួរបណ្តោយឱ្យកូនស្រីរបស់ខ្លួននៅម្នាក់ឯង ឬដើរពេលយប់តែម្នាក់ឯងទេ ហើយកុមារីខ្លួនឯងផ្ទាល់កុំឱ្យឆាប់ជឿពាក្យលួងលោមរបស់អ្នកដទៃខ្លាំងពេក។

## *គ.អ.ស.កសូមលើកយកករណីមួយដែលជនកើតអេដស៍បានរំលោភសេពសន្ថវៈលើកុមារីអាយុ៤ឆ្នាំមកបង្ហាញដូចខាងក្រោម*

ករណីនេះជារឿងមួយគួរអោយស្អប់ខ្ពើម និងគួរឱ្យសោកស្តាយបំផុត ដែលបុរសឈាមខ្មៅក្នុងសង្គមយើងម្នាក់បានប្រព្រឹត្តអំពើដ៏ថោកទាបមួយ គឺការចាប់រំលោភក្មេងស្រីអាយុ៤ឆ្នាំ ហើយអ្វីដែលគួរឱ្យរន្ធត់ទៀតនោះ គឺជនល្មើសជាមនុស្សកើតអេដស៍ផង។

ហេតុការនេះកើតឡើងកាលពីថ្ងៃទី៦ ខែកញ្ញា ២០០៥ កន្លងមកនេះនៅស្រុកជុំគីរី ខេត្តកំពត។

ជនជាប់ចោទនេះជាមន្ត្រីទាហាននៅវរសេនាតូចលេខ ១១២កងពលតូចលេខ១១ នៅតំបន់បាក់នឹម ភ្នំនារាយណ៍។ ជននេះមានអាយុ៤២ឆ្នាំ មានប្រពន្ធ និងកូនបីនាក់ជាអ្នករស់នៅភូមិឃុំច្រេស ស្រុកជុំគីរី ខេត្តកំពត។ ហើយកុមារីរងគ្រោះមានទីលំនៅភូមិនេះដែរ។

តាមសំដីរបស់ស្ត្រីដែលជាម្តាយកុមារីរងគ្រោះបានរៀបរាប់ប្រាប់ថា នៅពេលព្រឹកថ្ងៃកើតហេតុ គាត់ពីរនាក់ប្តីប្រពន្ធបានក្រោកពីដំណេក ហើយក៏រួតរះទៅស្ទូងនៅស្រែ ដោយទុកឱ្យកូនតូចៗចំនួន៣នាក់នៅចាំផ្ទះ។ លុះដល់ម៉ោង៨និង៣០នាទីព្រឹក ពេលដែលគាត់ដកសំណាបបាន ហើយវែកកាត់មុខផ្ទះ ពេលនោះកូនគាត់ម្នាក់អាយុ១ឆ្នាំយំ គាត់ក៏ឈប់ឱ្យកូនប្រុសពៅបៅ។ ស្ត្រីជាម្តាយបន្តថា បន្ទាប់ពីឈប់ឱ្យកូនបៅហើយ គាត់ក៏បានវែកសំណាបទៅស្រែរហូតដល់ម៉ោង៩ទើបប្តីគាត់ដាក់ពីភ្ជួរ ហើយត្រឡប់មកផ្ទះមុន តែប្តីគាត់មិនដឹងអ្វីទាំងអស់ព្រោះឃើញកូនស្រីអង្គុយលេងធម្មតា។ លុះម៉ោងជិត១១ថ្ងៃត្រង់ពេលគ្រួសារគាត់ជួបជុំគ្នាហូបបាយ ស្រាប់តែកូនស្រីរបស់គាត់និយាយថានាងឈឺត្រង់ប្រដាប់ភេទនៅពេលនោម។ ដោយឮកូននិយាយបែបនេះ គាត់ក៏សួរថា "ចុះកូនឯងឈឺអី"? ទើបកូនប្រាប់អំពីការចាប់រំលោភកាលពីព្រឹកនោះ។

ក្រោយពីឮកូនប្រាប់រឿងបែបនេះ គាត់ក៏ចាប់កូនមកពិនិត្យមើលទើបដឹងថា ប្រដាប់ភេទមានរបួស។ គាត់បន្តទៀតថា បើតាមកូនស្រីគាត់និយាយប្រាប់ ជនល្មើសដែលរំលោភកូនគាត់នោះគឺឈ្មោះជ្រក់ ហៅរឿន សុភណ្ឌ។ កូនស្រីគាត់បានប្រាប់ទៀតថា ទោះបីជានាងយំក៏ត្រូវជននោះគំរាមវាយដែរ ហើយលុះរំលោភរួចក៏រត់គេចខ្លួនបាត់ទៅ។

ម្តាយក្មេងស្រីរងគ្រោះប្រាប់ថា គាត់បាននាំកូនស្រីគាត់ទៅពិនិត្យនៅស្នងការប៉ូលិសខេត្ត ដើម្បីឱ្យដឹងប្រាកដថាតើរឿងនេះពិតមែនឬយ៉ាងណា។ ហើយលទ្ធផលអះអាងថា កូនស្រីគាត់ពិតជាបានទទួលរងនូវការរំលោភពិតមែន ហើយជនល្មើសរូបនោះ ក៏ត្រូវបានចាប់ខ្លួនហើយដែរកាលពីថ្ងៃទី៩កញ្ញា។

ករណីនេះយើងឃើញថា ជនល្មើសត្រូវបានចាប់ខ្លួនហើយ តែយើងនៅមិនទាន់ដឹងថា តើតុលាការនឹងកាត់ទោសជននោះបែបណានោះទេ៕

# ការប្រគល់រង្វាន់ដល់កុមារជាប់ចំណាត់ថ្នាក់នៃការប្រលងគំនូរ

កាលថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៥ គ.អ.ស.កបាន ចែករង្វាន់ដល់កុមារចំនួន១២នាក់ដែលបានជាប់ចំណាត់ថ្នាក់នៃការប្រលងគំនូរ នៅផ្ទះកុមារ។

កុមារចូលរួមក្នុងពិធីនោះមានចំនួន៣០នាក់ មកពីម៉ុំប្ញូរីកីឡា និងកុមាររស់នៅជុំវិញផ្ទះកុមារ។ កុមារទាំងអស់នេះជាកុមារក្នុងគ្រួសារក្រីក្រ និងកុមាររើសអេតចាយ។

គួររំលឹកថា ការប្រលងគំនូរនេះត្រូវបានរៀបចំដោយ គ.អ.ស.ក កាលពីថ្ងៃទី២២_២៣ មិថុនា ២០០៥ នៅផ្ទះកុមារ ដោយផ្តោតលើប្រធានបទ“ *ការលុបបំបាត់អំពើហិង្សាក្នុងគ្រួសារ*”។ កុមារដែលបានចូលរួមមានចំនួន៨៦នាក់ មានកុមារីចំនួន១៤នាក់ មកពីម៉ុំប្ញូរីកីឡា និងជុំវិញផ្ទះកុមារ។ កុមារមានអាយុចន្លោះពី៩ដល់១៧ឆ្នាំ រៀនថ្នាក់ពីទី១ ដល់ទី៨ នៅវិទ្យាល័យបាក់ទូក និងបឋមសិក្សាវត្តព្រះពុទ្ធ។ ហើយពួកគេត្រូវបានបែងចែកជា៣ក្រុមគឺក្រុម១ កុមារមានអាយុចន្លោះពី៩ដល់១២ឆ្នាំ ក្រុម២កុមារមានអាយុចន្លោះពី១៣ដល់១៥ឆ្នាំ និងក្រុម៣កុមារមានអាយុចន្លោះពី១៥ដល់១៧ឆ្នាំ។

កញ្ញា ពត ច័ន្ទនីកា អ្នកគ្រប់គ្រងផ្ទះកុមារនិយាយថា ការប្រលងគំនូរបានផ្តល់អត្ថប្រយោជន៍ជាច្រើនដល់កុមារគឺ កុមារអាចយល់ដឹងខ្លះៗ ថាតើអ្វីជាអំពើហិង្សាក្នុងគ្រួសារ? កុមារអាចយល់ដឹងអំពីផលប៉ះពាល់នៃអំពើហិង្សាមកលើផ្លូវកាយ និងផ្លូវចិត្ត។ កុមារអាចយល់ដឹងខ្លះៗក្នុងការដោះស្រាយប្រសិនបើមានអំពើហិង្សាក្នុងគ្រួសារ។ ផ្តល់ឱកាសដល់កុមារដើម្បីបញ្ចេញនូវស្នាដៃរបស់ពួកគេរៀងៗខ្លួន។ និងអាចធ្វើឱ្យយើងដឹងនូវអ្វីដែលកើតមាននៅក្នុងគ្រួសាររបស់គេ ឬរឿងរ៉ាវដែលគេបានជួបប្រទះ។

កញ្ញា ពត ច័ន្ទនីកាបន្តថា កុមារដែលបានជាប់ចំណាត់ថ្នាក់នៃការប្រលងគំនូរនេះ ត្រូវបានបែងចែកជា៣ក្រុមទៅតាមអាយុដែលបានកំណត់កាលពីពេលប្រលងគំនូរ គឺក្នុងក្រុមនីមួយៗមានកុមារចំនួន៣នាក់ ហើយមានពីលេខ១ដល់លេខ៣ និងមានកុមារ៣នាក់ទៀតត្រូវបានទទួលរង្វាន់លួងចិត្ត។

កុមារី ផាន់ រតនា អាយុ១៤ឆ្នាំជាប់ចំណាត់ថ្នាក់លេខ១ក្នុងការប្រលងគំនូរនោះបានប្រាប់ពីទស្សនៈផ្ទាល់ខ្លួនថា ពេលឃើញមានអំពើហិង្សាលើកុមារ កុមារផ្សេងទៀតដែលបានឃើញហេតុការណ៍នោះត្រូវទៅហៅប៉ូលិស ឬមេភូមិមកជួយឃាត់។





*កុមាររាំលេងកំសាន្តក្រោយពេលបញ្ចប់កម្មវិធី*

ចំណែកឯកុមារី សុខ ផានិត អាយុ១៤ជាប់ចំណាត់ថ្នាក់លេខ២និយាយថា “ខ្ញុំចង់ឃើញកុមាររស់នៅក្នុងគ្រួសារដែលគ្មានអំពើហិង្សា ព្រោះបើគ្រួសារនោះមានសុភមង្គលនោះកុមារទទួលបាននូវការសិក្សាល្អពីអ្នកគ្រូ និងមានមិត្តច្រើនទៀតផង”។

រីឯកុមារា គីម ហៀង អាយុ១៣ឆ្នាំ ប្រាប់ថា “ខ្ញុំចង់ឃើញមិត្តភក្តិរបស់ខ្ញុំរស់នៅក្នុងគ្រួសារដែលគ្មានអំពើហិង្សា។ ហើយសូមឱ្យអង្គការជួយលុបបំបាត់អំពើហិង្សា ព្រោះបើមានអំពើហិង្សាធ្វើឱ្យកុមាររៀនមិនចូល ពេលកំពុងរៀននឹកឃើញតែឪពុកវាយម្តាយ និងកុមារដែលជាមិត្តភក្តិរបស់ខ្ញុំ”។

នៅទីបញ្ចប់នៃការចែករង្វាន់នោះ ក៏មាននំ និងភេសជ្ជៈបន្តិចបន្តួចសំរាប់ឱ្យកុមារបរិភោគ និងរាំលេងកំសាន្តសប្បាយផងដែរ ដើម្បីបង្កនូវភាពស្និទស្នាលថែមទៀត៕

# អង្គការយុវជនខ្មែរបោះជំរំដើម្បីវប្បធម៌

## ១_ទស្សនវិស័យ

ប្រជាជនគ្រប់រូបនៅក្នុងប្រទេសកម្ពុជានឹងទទួលយកនូវស្មារតីស្ម័គ្រចិត្តក្នុងការអនុវត្តន៍សិទ្ធិកុមារ និងការគោរពគ្នាទៅវិញទៅមក។

## ២_បេសកកម្ម

_ធ្វើការតស៊ូមតិ និងពង្រីកចំនេះដឹងនៃការអនុវត្តន៍អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ តាមរយៈការលើកទឹកចិត្តចូលរួម និងការបញ្ចេញមតិរបស់កុមារ។

_ទទួលសមាជិកស្ម័គ្រចិត្តបណ្តុះបណ្តាលលើការទទួលខុសត្រូវ និងធ្វើជាគំរូក្នុងការអនុវត្តន៍សិទ្ធិកុមារ។

## ៣_ប្រវត្តិអង្គការ

ខេវ៉ាយស៊ីស៊ី គឺជាអង្គការក្រៅរដ្ឋាភិបាលមិនរកកម្រៃ មិនប្រកាន់បក្សពួក និងមិនទាក់ទងនិន្នាការនយោបាយ។ អង្គការនេះត្រូវបានបង្កើតឡើងនៅថ្ងៃទី០១ខែមករាឆ្នាំ២០០១ ធ្វើសកម្មភាពស្របទៅតាមលក្ខន្តិកៈ និងច្បាប់របស់ខេវ៉ាយស៊ីស៊ី ដែលបានចុះឈ្មោះជាមួយក្រសួងមហាផ្ទៃ MoI លេខ៣២១ ស.ជ.ណស្របតាមរដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជា។

## ៤_កម្មវិធី និងសកម្មភាពចំបងៗ

### កុមារៈ

អប់រំ និងតស៊ូមតិដើម្បីឱ្យមានការអនុវត្តន៍សិទ្ធិកុមារស្របទៅតាមអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ។ កម្មវិធីអង្គការខេវ៉ាយស៊ីស៊ី គឺពង្រីកបណ្តាញកុមារក្នុងសហគមន៍ទូទាំងប្រទេសកម្ពុជាក្នុងការជំរុញឱ្យមានការគោរពសិទ្ធិកុមារ និងអនុវត្តន៍សិទ្ធិកុមារនៅកម្ពុជា។ បច្ចុប្បន្នខេវ៉ាស៊ីស៊ីមានបណ្តាញកុមារចំនួន២កន្លែងគឺ

១_ខេត្តកណ្តាល ស្រុកពញាឮ ឃុំពញាពន់ (ភ្នំរាប) ដែលជាក្រុមកុមារសហគមន៍។

២_ខេត្តកំពង់ចាម ស្រុកកងមាស ឃុំស្តៅ ដែលជាក្រុមកុមារនៅក្នុងអនុវិទ្យាល័យ។

### យុវវ័យៈ

យុទ្ធនាការផ្សព្វផ្សាយក្នុងការកាត់បន្ថយការរីករាលដាលនៃជំងឺអេដស៍ ការជួញដូរផ្លូវភេទ ចំនេះដឹងផ្នែកយេនឌ័រ និងបណ្តុះបណ្តាលឱ្យយល់ដឹងអំពីអនុសញ្ញានានារបស់អង្គការសហប្រជាជាតិនៅកម្ពុជា។

### អាសយដ្ឋានទំនាក់ទំនង

លោក ខន សុវិធី នាយកប្រតិបត្តិ
ផ្ទះលេខ២៣៦ ផ្លូវលេខ៣៧៦ សង្កាត់បឹងកេងកង៣
ខ័ណ្ឌចំការមន ក្រុងភ្នំពេញ។
ទូរស័ព្ទលេខ ០១២ ៧៣៦ ១៦៦
ប្រអប់សំបុត្រស៊ីស៊ីស៊ីលេខ ៣៧៧
E-mail : info@kycc4peace.org
Website : www.kycc4peace.org

## មហាសំណើច

## សណ្តែកដីលីង

ផល្លាធ្វើការនៅក្នុងបន្ទប់ជាមួយអ៊ំស្រីចំណាស់ម្នាក់អាយុប្រហែល៦០ឆ្នាំ។

អ៊ំស្រីតែងដាក់សណ្តែកដីលីងមួយកូនស្បោងនៅលើតុធ្វើការរបស់គាត់។

ផល្លាចូលចិត្តញ៉ាំសណ្តែកដីលីងណាស់។ ឆ្លៀតពេលអ៊ំស្រីកំពុងប្រជុំ ផល្លាភ្លក់មួយគ្រាប់ពីរ «ហ្អេ! ឆ្ងាញ់! បើលីងថែមឱ្យស្ងួតបន្តិច និងថែមអំបិលបន្តិច មិនដឹងជាឆ្ងាញ់យ៉ាងណាទេ!!!»។

ផល្លាជ្រុលមាត់ ញ៉ាំអស់កន្លះថង់។ ពេលអ៊ំស្រីត្រឡប់មកវិញ ផល្លាសារភាពថា «សុំទោសអ៊ំ! ឃ្លានពេក ខ្ញុំញ៉ាំដោយមិនបានសួរ»។ អ៊ំតបថា «អូ! ញ៉ាំចុះ! អ៊ំមានធ្មេញឯណាទៅទំពានោះ អ៊ំបានតែជញ្ជក់ៗយកតែអំបិលហ្នឹង!»។

តមកពីទំព័រទី២

(តំណាងមកពីអង្គការស៊ីកាស្វា) ជាតំណាងកុមារកម្ពុជា បានទៅចូលរួមក្នុងសន្និសីទពិភពលោកនេះជាលើកទី២ និយាយថា នេះជាលើកទី២ហើយដែលគ. អ. ស. កបានបញ្ជូននាងឱ្យទៅចូលរួមក្នុងសន្និសីទនេះ។

ប្អូនស្រីនិយាយទៀតថា អ្វីដែលគួរជាទីមោទនៈនោះគឺថា ប្អូនស្រីត្រូវបានគេដាក់បញ្ចូលទៅក្នុងក្រុមការងារមួយដែលនឹងរៀបចំដាច់ដោយឡែកពី Global March ដែលគេហៅថា International Group Against Child Labor ជាក្រុមការងារអន្តរជាតិមួយ។ ប្អូនស្រីជាសមាជិកមួយរូបនៅក្នុងក្រុមការងារនេះ ដូច្នេះរាល់ព័ត៌មាន សកម្មភាពផ្សេងៗដែលក្រុមការងារនេះធ្វើ គេនឹងទំនាក់ទំនងមកប្អូនស្រីផ្ទាល់។

មុននឹងបញ្ចប់ ប្អូនស្រីរតនាសូមថ្លែងអំណរគុណចំពោះ គ. អ. ស. កដែលបានបញ្ជូននាងទៅចូលរួមក្នុងសន្និសីទនេះ ហើយសូមសំណូមពរជួយពង្រឹង*បណ្តាញកុមារអ្នកតស៊ូមតិ* ឱ្យមានដំណើរការល្អទៅមុខទៀត ដើម្បីឱ្យកុមារដទៃទៀតបានចូលរួមបញ្ចេញមតិ និងទស្សនៈរបស់ពួកគេ៕

## សាររបស់កុមារក្នុងឱកាសសន្និសីទ

*កុមារត្រូវទទួលបាននូវការអប់រំគ្រប់កាលទេសទាំងអស់!*

*កុមារជាកូនរបស់អ្នក ជាកេតនភ័ណ្ឌដ៏មានតំលៃរបស់ជាតិ និងពិភពលោក*

*បំផ្លាញអនាគតកុមារ ក៏ដូចជាបំផ្លាញអនាគតកូនខ្លួនឯង*

*បំផ្លាញជាតិខ្លួនឯង ក៏ដូចជាបំផ្លាញពិភពលោកទាំងមូល!*

*កុមារី វង្ស រតនា តំណាងកុមារកម្ពុជា*



## គណៈកម្មការពិនិត្យ

- លោក ជា ពីដែន
- លោក មាស សំណាង
- លោក ម៉ិច សុខា
- លោក យឹម ប៉ូ
- លោកស្រី ថូ ថារី
- លោក ស៊ុំ ចំរុង

## អ្នកគ្រប់គ្រងព័ត៌មាន

- កញ្ញា ផ ស៊ីវហួយ

## គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាល ដើម្បីសិទ្ធិកុមារ

អាសយដ្ឋានទំនាក់ទំនង: ផ្ទះកុមារ លេខ៨A
ផ្លូវ១៣៨ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ
ទូរស័ព្ទ : (៨៥៥) ២៣ ៨៨២ ៤១២
ទូរសារ : (៨៥៥) ២៣ ៨៨២ ៤១២
អ៊ីមែល : ch.ngocrc@online.com.kh